## រឿងទី១០៖ យ៉ាកុប ២ (យ៉ាកុបនៅបេតអែល)

**ខគម្ពីរ៖ លោកុប្បត្តិ២៨៖១៥**

ចំពោះយើងផ្ទាល់ យើងនឹងស្ថិតនៅជាមួយអ្នក យើងនឹងថែរក្សាអ្នក គ្រប់ទីកន្លែងដែលអ្នកទៅ ហើយ យើងនឹងនាំអ្នកត្រឡប់មកទឹកដីនេះវិញ ដ្បិតយើងមិនបោះបង់ចោលអ្នកឡើយ គឺយើងនឹងសម្រេចអ្វីទាំងអស់តាមពាក្យដែលយើងសន្យានេះ»។

យ៉ាកុបបានលួចយកពរពីឪពុក និងសិទ្ធជាបងច្បងរបស់អេសាវ ដូច្នេះហើយទើបទទួលបានការស្អប់ពីបងអេសាវ។ យ៉ាកុបត្រូវបង្ខំចិត្ត រត់គេចពីបងប្រុសទៅនៅទីដ៏ឆ្ងាយ។

គាត់បានរត់គេចខ្លួនទៅផ្ទះរបស់អ៊ំគាត់នៅកន្លែងដ៏សែនឆ្ងាយ។ យ៉ាកុបកាន់តែមិនស្រួលក្នុងចិត្តពីមួយថ្ងៃទៅមួយថ្ងៃ។

ដល់យប់ងងឹងមកដល់ យ៉ាកុបបានយកថ្មមកធ្វើជាខ្នើយកើយ រួចក៏ដេកលក់បាត់ទៅ។

យ៉ាកុបានយល់សុបិន។ នៅក្នុងសុបិន ឃើញមានជណ្តើរមួយបញ្ឈរលើផែនដី ចុងវាខ្ពស់រហូតដល់មេឃ។

នៅលើនោះមានទេវតាកំពុងនាំគ្នាចុះឡើងតាមជណ្តើរនោះ។

ពេលនោះ ព្រះជាម្ចាស់ទ្រង់គង់នៅលើជណ្តើរនោះមានបន្ទូលទៅយ៉ាកុបថា៖ «យ៉ាកុបអើយ យើងជាព្រះអម្ចាស់ ដ្បិតយើងនឹងប្រគល់ទឹកដីដែលអ្នកដេកលើនេះដល់អ្នក និងពូជពង្សរបស់អ្នក។ ពូជពង្សរបស់អ្នកនឹងមានចំនួនច្រើនដូចធូលីដី។ គ្រប់កន្លែងដែលអ្នកទៅ យើងនឹងការពារអ្នក យើងនឹងមិនបោះបង់ចោលអ្នកឡើយ»។

យ៉ាកុប ភ្ញាក់ឡើងភ្លាម ក៏យកថ្មដែលគាត់បានកើយនោះមកបញ្ឈរថ្វាយការអរព្រះគុណដល់ព្រះជាម្ចាស់។

ហើយគាត់បានដាក់ឈ្មោះកន្លែងនោះថា «បេតអែល»។

ដល់ពេលមួយ យ៉ាកុបក៏បានទៅដល់ផ្ទះឡាបាន់ដែលត្រូវជាអ៊ំរបស់គាត់។

គាត់បានឃើញរ៉ាជែលជាកូនស្រីរបស់អ៊ំ ហើយបានជាប់ចិត្តនឹងនាងពេលជួបដំបូង។

យ៉ាកុបបាននិយាយទៅអ៊ំគាត់ថា៖ «លោកឪពុកអើយ បើលោកឪពុកឱ្យរ៉ាជែលជាកូនពៅរៀបការនឹងខ្ញុំ ខ្ញុំនឹងនៅបម្រើលោកឪពុកចំនួនប្រាំពីរឆ្នាំ។»។

ប្រាំពីរឆ្នាំក៏បានកន្លងផុតទៅ។ ដោយព្រោះយ៉ាកុបស្រឡាញ់រ៉ាជែលខ្លាំងពេក ទើបមានអារម្មណ៍ប្រាំពីរឆ្នាំនេះគឺមិនយូរទេសម្រាប់គាត់។

ប៉ុន្តែ ឡាបាន់ជាអ៊ំ មិនបានឱ្យរ៉ាជែលរៀបការជាមួយយ៉ាកុបទេ គឺឱ្យលេអាជាបងស្រីរៀបការជំនួសវិញ។

ហើយឡាបាន់បាននិយាយទៅយ៉ាកុបថា៖ «បើក្មួយធ្វើការឱ្យអ៊ំប្រាំពីរឆ្នាំទៀត នោះអ៊ំនឹងឱ្យរ៉ាជែលទៅក្មួយធ្វើជាប្រពន្ធ»។

យ៉ាកុបបានប្រឹងប្រែងធ្វើការ តាមអ្វីដែលឡាបាន់បាននិយាយ។

ប្រាំពីរឆ្នាំក៏បានកន្លងផុតទៅ ទីបំផុត យ៉ាកុបក៏បានរៀបការជាមួយរ៉ាជែលជាមនុស្សដែលគាត់ស្រឡាញ់។

យ៉ាកុបបានរៀបការជាមួយរ៉ាជែល និងលេអាហើយបង្កើតបានកូនប្រុសជាច្រើន។

ហើយពួកគេក៏មានទ្រព្យសម្បត្តិជាច្រើនតាមរយៈព្រះពររបស់ព្រះជាម្ចាស់។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. ហេតុអ្វីបានជាអេសាវមានគំនុំនឹងយ៉ាកុប?

---

b. តើយ៉ាកុបបានហៅទីកន្លែងដែលគាត់បានយកដុំថ្មដែលលោកកើយនោះ មកដាក់បញ្ឈរជាស្តូប បន្ទាប់ពីបានជួបនឹងព្រះជាម្ចាស់នៅតាមផ្លូវទៅផ្ទះរបស់លោកអ៊ំឡាបាននោះថាអ្វី?

---

c. សូមអានគម្ពីរលោកុប្បត្តិ ២៨៖១៥-២២ រួចឆ្លើយសំណួរ។ តើលោកយ៉ាកុបបានសន្យាថានឹងថ្វាយអ្វីដល់ព្រះជាម្ចាស់?

---

d. តើអ្នកបានរៀនអ្វីខ្លះពីដំណើររឿងរបស់លោកយ៉ាកុបនេះ?

---



- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (លោកុប្បត្តិ២៨៖១៥)

> ចំពោះយើងផ្ទាល់ យើងនឹងស្ថិតនៅជាមួយអ្នក យើងនឹងថែរក្សាអ្នក គ្រប់ទីកន្លែងដែលអ្នកទៅ ហើយយើងនឹងនាំអ្នកត្រឡប់មកទឹកដីនេះវិញ ដ្បិតយើងមិនបោះបង់ចោលអ្នកឡើយ គឺយើងនឹងសម្រេចអ្វីទាំងអស់តាមពាក្យដែលយើងសន្យានេះ»។

**សកម្មភាពទី២** សូមរកមើលចំណុចខុសគ្នានៃរូបភាពខាងក្រោមឱ្យបានចំនួន១០។





**សកម្មភាពទី៣** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



www.kidsworship.kr

Ministry of Christian Publishing

ឈ្មោះ